# ព្រឹត្តិបត្រព័ត៌មាន

## សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង

លេខ០៣ ខែមីនា ឆ្នាំ២០២៤



ហ្វេសប៊ុកផេក៖ វិទ្យាល័យ ហ៊ុនសែន ពាមជីកងជំនាន់ថ្មី
លេខទូរសព្ទ៖ 096 7273 921/ 087 609 156
គេហទំព័រ www.pck.ngs.edu.kh
អ៊ីម៉ែល៖ ngspckhighschool@gmail.com


## មាតិកា


- ប្រឡងឆមាសលើកទី១ ថ្នាក់ទី៧, ៨, ១០ និងថ្នាក់ទី១១
- អបអរសាទរខួបលើកទី113 ទិវានារីអន្តរជាតិ ០៨ មីនា ២០២៣
- ប្រឡងឆមាសលើកទី១ ថ្នាក់ទី៩
- ការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីមួយឆមាសកន្លងមក
- ការអប់រំផ្លូវចិត្តតាមបែបព្រះពុទ្ធសាសនា
- ប្រឡងឆមាសលើកទី១ ថ្នាក់ទី១២
- ការជ្រើសរើសអាជីពជាគ្រូបង្រៀន និងការវិវត្តខ្លួនក្លាយជាគ្រូបង្រៀនល្អ


## ប្រឡងឆមាសលើកទី១ ថ្នាក់ទី៧, ៨, ១០ និងថ្នាក់ទី១១

ពាមជីកង៖ នៅថ្ងៃអង្គារ ១០រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំការប្រឡងឆមាសលើកទី១ ដល់សិស្សានុសិស្សថ្នាក់ទី៧, ៨, ១០ និងទី១១ សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ នៅតាមអគារនីមួយៗរបស់វិទ្យាល័យ ហ៊ុន សែន ពាមជីកង ដោយការប្រឡងមានភាពតឹងរឹងបំផុត។ នៅតាមបន្ទប់ប្រឡងនីមួយៗមានគណៈកម្មការអនុរក្សចំនួនពីរនាក់ និងនៅតាមអគារប្រឡងនីមួយៗមានគណៈកម្មការត្រួតពិនិត្យអគារចំនួនមួយនាក់។ ជាមួយគ្នានេះដែរ ការប្រឡងបេក្ខជនទាំងអស់ត្រូវបានរៀបឱ្យប្រឡងជាមួយគ្នាគ្រប់កម្រិតថ្នាក់ ដែលបន្ទប់នីមួយៗមានសិស្សថ្នាក់ទី៧ប្រឡងជាមួយសិស្សថ្នាក់ទី៨ និងសិស្សថ្នាក់ទី១០ប្រឡងជាមួយសិស្សថ្នាក់ទី១១ ហើយនិងការបំពេញតួនាទីយ៉ាងយកចិត្តទុកដាក់ពីអនុរក្សទៀតនោះ សិស្សានុសិស្សទាំងអស់បានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការប្រឡងលើវិញ្ញាសានីមួយៗ និងពោរពេញដោយក្តីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់បានគោរពនូវបញ្ញាត្តិក្នុងពេលប្រឡងបានយ៉ាងខ្ជាប់ខ្ជួន។














# អបអរសាទរខួបលើកទី113 ទិវានារីអន្តរជាតិ ០៨ មីនា ២០២៣




នាថ្ងៃអង្គារ ៣ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ ក្រុមសិស្សTechnovation Girl នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង បានចូលរួមពិធីអបអរសាទរខួបលើកទី113 ទិវានារីអន្តរជាតិ ០៨ មីនា ២០២៣ ក្រោមប្រធានបទ “ស្ត្រី និង ក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ថ្នាក់ដឹកនាំក្រសួង ភ្ញៀវកិត្តិយស បុគ្គលិកអប់រំ សមាជិក សមាជិកា និងគរុសិស្ស នៅវិទ្យាស្ថានជាតិអប់រំ។








## ប្រឡងឆមាសលើកទី១ ថ្នាក់ទី៩

ពាមជីកង៖ នៅថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ សិស្សានុសិស្សថ្នាក់ទី៩ បានប្រឡងឆមាសលើកទី១ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ នៅតាមអគារនីមួយៗនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដោយការប្រឡងមានភាពតឹងរឹងបំផុត។ នៅតាមបន្ទប់ប្រឡងនីមួយៗ មានគណៈកម្មការអនុរក្សចំនួនពីរនាក់ និងនៅតាមអគារប្រឡងនីមួយៗមានគណៈកម្មការត្រួតពិនិត្យអគារចំនួនមួយនាក់។ នៅក្នុងការប្រឡងឆមាសលើកទី១ របស់សិស្សថ្នាក់ទី៩ បេក្ខជនប្រឡងបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការធ្វើវិញ្ញាសារបស់ខ្លួន និងពោរពេញដោយក្ដីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់បានគោរពនូវបញ្ញត្តិក្នុងពេលប្រឡងបានយ៉ាងខ្ជាប់ខ្ជួន។




## ការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីមួយឆមាសកន្លងមក

ប្រជុំផ្សព្វផ្សាយពី៖

-ការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីមួយឆមាសកន្លងមក -របាយការណ៍វិភាគទាន ការគ្រប់គ្រង និងប្រើប្រាស់ថវិការវិភាគទាន

-ភាពខុសគ្នារវាងសាលារៀនជំនាន់ថ្មី និងសាលារៀនធម្មតាដល់អាណាព្យាបាលសិស្ស

-ព្រមទាំងផ្សព្វផ្សាយពីផែនការប្រមូលវិភាគទានលើកទី២ក្នុងខែមេសា ឆ្នាំ២០២៤ ដោយមានការចូលរួមពីសំណាក់លោក ប៉ូច ឆាយ តំណាងអាជ្ញាធរដែនដី និងគណៈកម្មការគ្រប់គ្រងសាលារៀន ផងដែរ ។






# ការអប់រំផ្លូវចិត្តតាមបែបព្រះពុទ្ធសាសនា



ចតុស្តម្ភនៃការអប់រំនៅកម្ពុជា បានរួមចំណែកបណ្តុះមនុស្សឱ្យរៀនរស់ដោយពហុចំណេះ រួមមាន រៀនដើម្បីចេះដឹង, រៀនដើម្បីចេះធ្វើ, រៀនដើម្បីមានសីលធម៌ល្អ និងរៀនដើម្បីចេះរួមរស់ជាមួយគ្នា។ ក្នុងនោះ ការរៀនដើម្បីមានសីលធម៌ល្អ គឺជាផ្នែកសំខាន់មួយនៅក្នុងចតុស្តម្ភនៃការអប់រំ ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងយកចិត្តទុកដាក់។

នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ក្របដោយ សីលធម៌, សមធម៌ និងបរិយាបន្ន គឺជាគោលដៅយុទ្ធសាស្ត្រមួយរបស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដោយក្នុងនោះរាជរដ្ឋាភិបាលបានផ្តោតអាទិភាពលើ ៖ ការពង្រឹង និងការបង្កើនកិច្ចសហការក្នុងការអប់រំអំពី សីលធម៌, គុណធម៌ និងសុជីវធម៌ ដល់សិស្ស និស្សិត និងយុវជន ទាំងក្នុង និងក្រៅប្រព័ន្ធអប់រំ, រៀបចំផែនទីបង្ហាញផ្លូវ ដើម្បីបណ្តុះទម្លាប់មានសីលធម៌, គុណធម៌ និងសុជីវធម៌ និងទម្លាប់គោរពច្បាប់ និងវិន័យ និងបញ្ចូលការអប់រំអំពីព្រះពុទ្ធសាសនា និងផ្នែកសិល្បៈវប្បធម៌ខ្មែរ ទាំងរូបី និងអរូបី ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ព្រមទាំងផ្សព្វផ្សាយ និងបញ្ជ្រាបទៅគ្រប់ក្រសួងស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ជាមួយគ្នានេះ ការអប់រំសីលធម៌តាមបែបព្រះពុទ្ធសាសនានៅតាមសាលារៀន កំពុងដើរតួនាទីសំខាន់ក្នុងការបណ្តុះចរិយាធម៌កុមារ និងយុវជន។ ការអប់រំសីលធម៌ដល់សិស្សានុសិស្ស ជារឿងសំខាន់ណាស់ ដើម្បីឱ្យដឹងថា អ្វីខុស អ្វីត្រូវ អ្វីល្អ អ្វីអាក្រក់ អ្វីគួរធ្វើ និងមិនគួរធ្វើ ព្រមទាំងតម្រង់ទិសកុំឱ្យភ្លើតភ្លើនក្នុងប្រការណាមួយ។ កាលណាយើងស់នៅក្នុងសង្គមខ្មែរ ត្រូវអប់រំ សីលធម៌ សុជីវធម៌តាមបែបប្រពៃណីដូនតាផង ហើយក៏ត្រូវអប់រំសីលធម៌សិស្សានុសិស្សតាមបែបព្រះពុទ្ធសាសនាផង ដើម្បីឱ្យដឹងបាប ដឹងបុណ្យ ដឹងសីល៥ ដឹងផ្លូវកណ្តាល ឱ្យស្គាល់ធម្មជាតិរបស់មនុស្សខ្លួនឯង កើត ចាស់ ឈឺ ស្លាប់ ត្រូវកាត់បន្ថយការលោភលន់ ចេះអត់ធ្មត់ អត់ឱនឱ្យគ្នាទៅវិញទៅមក។

ដូចនេះហើយទើប**វិទ្យាល័យ ហ៊ុន សែន ពាមជីកង** បានអប់រំផ្លូវចិត្តតាមបែបពុទ្ធសាសនាដល់សិស្សានុសិស្សទាំងអស់។ ការអប់រំនេះធ្វើឡើងក្នុងគោលបំណង ដើម្បីឱ្យសិស្សមានសីលធម៌ក្នុងសង្គម ចេះគោរពចាស់ទុំ ឪពុកម្តាយ ត្រកូលរៀបច្បង ស្គាល់តួនាទីរបស់ខ្លួន ក្នុងនាមជាមនុស្ស ឬជាពលរដ្ឋនៃប្រទេសដែលមានវប្បធម៌ខ្ពង់ខ្ពស់ ស្គាល់ពីតម្លៃនៃព្រះពុទ្ធសាសនាក្នុងការអប់រំ និងដឹកនាំមនុស្សសត្វឱ្យបានសេចក្តីសុខ ឱ្យចេះស្រឡាញ់ និងចេះអភិរក្សវប្បធម៌ប្រពៃណីជាតិរបស់ខ្លួន លុបបំបាត់ភាពអនាចារផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសង្គមជាតិ ឱ្យមានទំនាក់ទំនងល្អក្នុងសង្គម មានអាកប្បកិរិយាចរិយា មារយាទ សីលធម៌ និងសុជីវធម៌ល្អ សាបព្រោះ និងបណ្តុះពូជមនុស្សល្អក្នុងសង្គមឱ្យបានច្រើន និង លុបបំបាត់អំពើអាក្រក់ទាំងឡាយទាំងពួង៕





# ប្រឡងឆមាសលើកទី១ ថ្នាក់ទី១២



ពាមជីកង៖ នៅថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ សិស្សានុសិស្ស ថ្នាក់ទី១២ បានប្រឡងឆមាសទី២ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ នៅក្នុងវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដោយមានភាពតឹងរឹងបំផុត។ នៅតាមបន្ទប់ប្រឡងមានគណៈកម្មការអនុរក្សចំនួនពីរនាក់ គណៈកម្មការត្រួតពិនិត្យអគារមួយនាក់ ដើម្បីត្រួតពិនិត្យការប្រឡងឆមាសទី២។ សិស្សានុសិស្សបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការប្រឡងលើវិញ្ញាសានីមួយៗ និងពោរពេញដោយក្តីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ បេក្ខជនគ្រប់បន្ទប់បានគោរពនូវបញ្ញាត្តិក្នុងពេលប្រឡងបានយ៉ាងល្អខ្ជាប់ខ្ជួន។








# ការជ្រើសរើសអាជីពជាគ្រូបង្រៀន និងការវិវត្តខ្លួនក្លាយជាគ្រូបង្រៀនល្អ



កម្មវិធីប្រឹក្សាអាជីពនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកងសាលារៀនជំនាន់ថ្មី នៅព្រឹកថ្ងៃសុក្រ ៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ កម្មវិធីប្រឹក្សាអាជីពបានបើកវគ្គសិក្ខាសាលាតម្រង់ទិសដល់សិស្សានុសិស្ស ថ្នាក់ទី១២ លើប្រធានបទ "ការជ្រើសរើសអាជីពជាគ្រូបង្រៀន និងការវិវត្តខ្លួនក្លាយជាគ្រូបង្រៀនល្អ" កម្មវិធីនេះដែរ ចូលរួមធ្វើបទបង្ហាញដោយលោក ឃុយ ម៉េងឃី គ្រូបង្រៀននៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង និងជាគ្រូបង្រៀនជ័យលាភីគ្រូបង្រៀនល្អចំណាត់លេខលេខ២ទូទាំងប្រទេស និងសម្របសម្រួលដោយអ្នកគ្រូ អាត ណារី គ្រូប្រឹក្សាអាជីពប្រចាំវិទ្យាល័យ ។

មិនតែប៉ុណ្ណោះ វាគ្មិនបានចែកសំណេរតែងសេចក្តី ដែលជាស្នាដៃផ្ទាល់របស់លោកដល់សិស្សជាការលើកទឹកចិត្តបន្ថែមទៀត ។



















